





# PUBLIC CHARGE COMMUNITY EDUCATION SHEET

## តើពាក្រ PUBLIC CHARGE មាននីយាងណា?

Public charge គឺជាពាក្រដែលមន្ត្រីអន្តោប្រវែសសំដៅទៅប្រជាពលរដ្ឋដែលពឹងពាក់ជំនួយកិច្ចសង្គ្រោះពីរដ្ឋាភិបាល សំរាប់ជាសេចក្តីឱបត្ថម្ភតំលៃចាំហាច់នៃការរស់នៅរាល់ថ្ងៃ។ នៅថ្ងៃនេះ មន្ត្រីផ្លូវការកំពង់សង្កេតមើលទៅលើ សេចក្តីកត្តាជាច្រើនប្រភេទក្នុងពេលវីនិច្ឆ័យថាតើជនម្នាក់នោះអាចទំនងគួរជាជន public charge ក៏ប៉ន្តែកម្មវីធីប្រយោ ជន៍នៃសាធារណៈដែលគេបានចាត់ទុកក្នុងផ្នែកនេះបានចេញតែពីកម្មវីធីប្រាក់ជំនួយសង្គ្រោះ ដូចជាកម្មវីធី (Temporary Assistance for Needy Families) និងកម្មវីធីថែរក្សាយោងវែងនៅមន្ទីរព្យាបាល(long-term nursing home care)ដែលរដ្ឋាភីបាលបានចេញថ្លៃជាជំនួយអោយ។

## តើការផ្លាស់ប្តូរទាំងអស់នេះនឹងអាចមានដូចម្តេច?

ច្បាប់គ្រប់គ្រង public charge ទាំងអស់នេះមិនទាន់មានការផ្លាស់ប្តូរនៅឡើយទេ នៅក្នុងប្រទេសសហរដ្ឋអាមេរិច(U.S.) ។ ប៉ុន្តែ ក្រសួងសន្តិសុខមាតុភូមិ Department of Homeland Security (DHS) ចង់ធ្វើអោយ public charge ជាការញែកធាតុយាងតឹងរឹង ហើយគេក៏ចង់ដាក់ ទម្ងន់ជាច្រើនទៅលើជនមួយចំនួន នៅលើខាង អាយុ ប្រាក់ចំណូល ស្ថានភាពសុខភាព នឹងកម្រិតភាសាអង់គ្លេសរបសគេម្នាក់ៗ ពួកគេក៏ចង់បូករួមចំនែកខ្លះៗទៅលើកម្មវីធី សុខភាព អាហារបំប៉ន ទីលំនៅដ្ឋាន ជាមួយការវីនិច្ឆ័យទាំងអស់នេះផងដែល។ ការរួមបញ្ចូលទាំងអស់នេះមានទៅលើកម្មវីធី non-emergency Medicaid  ពេទ្យគ្មានអាសន្ន Medicare Part D Low-Income Subsidy (នេះជាការជួយទៅមនុស្សអត់មានប្រាក់ចំណូលច្រើនដែលមិនមានលទ្ធភាពទិញថ្នាំពេទ្យ) កម្មវីធី Supplemental Nutrition Assistance Program (SNAP) ឬ កម្មវីធី food stamps កម្មវីធី Section 8 housing vouchers និង  កម្មវីធីឱយប្រាក់ជំនួយទីលំនៅដ្ឋាន subsidized public housing។

## តើការផ្លាស់ប្តូរទាំងអស់នេះអាចប៉ះពាល់ទៅលើអ្នកណាដែ?

### ការផ្លាស់ប្តូរទាំងអស់នេះអាចប៉ះពាល់ទៅលើ:

- ពលរដ្ឋដែលកំពង់ដាក់ពាក្រស្នើសុំសិទ្ធរស់នៅដែលហៅថា lawful permanent residents ( LPR ឬ Green Card holders) នៅក្នុងប្រទេសសហរដ្ឋអាមេរិច(U.S.)។
- ពលរដ្ឋដែលជាអ្នក LPRs ក៏ប៉ន្តែអ្នកបានទៅក្រៅប្រទេសសហរដ្ឋអាមេរិចលើសរយះពេល ៦ខែ ហើយអ្នកចង់ត្រលប់ចូលមកប្រទេសសហរដ្ឋអាមេរិច (U.S.) វីញ។
- អ្នកដែលមិនមែនជាជនអន្តោប្រវេសន៍ហៅថា Nonimmigrant visa holders (ដូចជា កូនសិស្ស ជនទេសចរ អ្នកធ្វើការបណ្តោះអាសន្ន) ហើយអ្នចទាំងអស់នេះចង់បានការរស់នៅបន្តរទៅទៀត ឬ ចង់ដូរវីហ្សា(visa) ទៅជាអ្វីផ្សេងទៀត។
- ជនជាតិនៅក្រៅប្រទេសដែលចង់ស្វែងរកការចូលមក ឬការចូលមកវីញម្តងទៀត

### ការផ្លាស់ប្តូរទាំងអស់នេះមិនបានប៉ះពាល់ទៅលើ:

- ពលរដ្ឋដែលកំពង់ដាក់ពាក្រសុំចូលសញ្ជាតិ
- ពលរដ្ឋដែលបានចូលសញ្ជាតិហើយ

### បន្ថែមទៀត ការផ្លាស់ប្តូរទាំងអស់នេះមិនបានប៉ះពាល់ទៅលើក្រុមអន្តោប្រវែសន៍ទាំងឡាយនេះទេ:

- ជនភៀសខ្លួន
- ជនសុំសិទ្ធជ្រកកោន
- ជនដែលបានរងគ្រោះខាងការជួញដូរមនុស្ស ខាងអំពើហឹង្សារ និងជនរងគ្រោះ ឬជនសាក្សីនៃបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ហើយអ្នកទាំងអស់នេះកំពុងដាក់ពាក្រសុំវីហ្សា ឬបានទទួលវីហ្សាហើយដែលហៅថា (T or U visa)

*This resource was developed by Asian Americans Advancing Justice – Los Angeles, 10/17/18.*

**បន្ថែមទៀត ការផ្លាស់ប្តូរទាំងអស់នេះមិនបានប៉ះពាល់ទៅលើក្រុមអន្តោប្រវែសន៍ទាំងឡាយនេះទេ:**

- ស្ត្រីជនរងគ្រោះនៅក្នុងកម្មវីធី Violence Against Women Act (VAWA) ដែលមានសិទ្ធសុំដាក់ពាក្រ្យសុំនៅក្លួនអែង។
- អ្នកបុគ្គលិសំខាន់ធនិតិជនអន្តោប្រវែសន៍
- នឹងក្រុមមួយជំនួនទៀតដែលមានទំនាក់ទំនងជាពិសេសជាមួយសហរដ្ធអាមេរិច(U.S.) ឬ ជនដែលបានមកដល់ក្នុងប្រទេសនេះពីកម្មវីធីសប្បុរសជនមួយជំនួនខ្លះ។

## តើកាផ្លាស់ប្តូរទាំងអស់នេះ អាចកើតឡើងនៅពេលណាដែល?

ការស្នើសុំនៃការផ្លាស់ប្តូរទាំងអស់នេះ បានកើតឡើងនៅក្នុងសហាព័ន្ធចុះឈ្មោះ Federal Register នៅលើថ្ងៃទី១០ ខែ តុលា ឆ្នាំ ២០១៨ ហើយសាធារណៈ និងបានឪកាសផ្តល់ជូនមតិយបល់សរសេទៅវីញ សំរាប់60ថ្ងៃនៅក្នុងអំឡុងពេលដំណើរការមួយ ដែលហៅថា រយៈពេលសាធារណៈផ្តល់មតិយោបល់ (the public comment period)។ រដ្ឋាភិបាលត្រូវតែមានតម្រវការ ពិនិត្យមតិណាមួយដែលមានជាលក្ខណះពិសេស ហើយរដ្ឋាភិបាលនឹងត្រូវឆ្លើយតបពីមតិទាំងអស់នោះទៅវីញ មុនពេលធ្វើការសម្រេចចិត្តទៅលើច្បាប់វីនិច្ឆ័យចុងក្រោយ។ ក្នុងចំនួនសរុបដំណើរធ្វើការវីនិច្ឆ័យទាំងអស់នេះ គេនិងអាចត្រូវចំណាយពេលជាបីបួនខែ ឬច្រើនពេលថែមទៀត។ អ្នកគួរតែបន្តការចុះឈ្មោះចូល និងការប្រើប្រាស់លើកម្មវីធី សុខភាព អាហារបំប៉ន ទីលំនៅដ្ឋាន ដែលជាការសំខាន់សំរាប់សុខភាព និងសុខុមាលភាពរបស់អ្នក។ ឥឡូវនេះ ការផ្លាស់ប្តូរទាំងអស់នេះមិនទាន់មានការកើតឡើងនៅក្នុងប្រទេសសហរដ្ធអា
មេរិច (U.S.) ហើយមានតែកម្មវីធីប្រាក់ជំនួយ និងកម្មវីធីថែរក្សាយាងវែងនៅមន្ទីរព្យាបាលប៉ុន្នោះទេ និងអាចចាត់ទុកថាអ្នកទាំងអស់នើគឺជាជន public charge នៅពេលគេធ្វើការត្រួតពិនិត្រ។

## តើច្បាប់ផ្លាស់ប្តូរថ្មីនេះអាចប៉ះពាល់ដល់ខ្ញុំយាងណាដែល?

នៅពេលបុគ្គលម្នាក់នុស្សក្លាយជាជន public charge មន្ត្រីអន្នោប្រវែសន៏និងត្រូវយកកត្តា អាយុ ខាងសុខភាព ទ្រព្យសកម្ម ប្រាក់ចំណូល ស្ថានការណ៍របស់គ្រសារអ្នក ការសិក្សាចំណេះដឹង និងភាពជំនាញការផ្សេងៗ ជាច្រើនទាំងអស់នេះយកមកបូករួមពិនិត្យឡើងវិញ។ការសំរាច់វិនិច្ឆ័យពីការចារណានេះត្រូវធ្វើការវិនិច្ឆ័យទៅលើស្ថានភាពរបស់បុគ្គលផ្ទាល់ខ្លួនម្នាក់ ចេញពីការពិចារណាទៅលើកត្តាជាច្រើនទៀតផ្សេងទៀត មិនមែនមើលទៅតែចំណុចមួយ ដូចជាសេចក្តីថាតើអ្នកបុគ្គលនោះបានប្រើការជំនួយពីសាធារណះរដ្ធណាមួយទេ។

## តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីបញ្ឈប់ការផ្លាស់ប្តូរទាំងអស់នេះកុំអោយកើតឡើង?

សូមលោកអ្នកនិយាយប្រាប់អំពីរឿងរបស់លោកអ្នក។ អ្នកអាចសរសេរសំបុត្រផ្ញើទៅក្នុងកំលុងពេលសាធារណៈផ្តល់មតិយោបល់ (the public comment period)។ យើងខ្ញុំបានព្យាយាមធ្វើអោយអ្នកមានការងាយស្រួលនៅពេលអ្នកដាក់មតិយោបល់ដោយបានបង្កើត បណ្តាញគេហទំព័រសំរាប់អ្នកនៅពេលអ្នកផ្ញើមតិយោបល់ទៅក្រសួងការពារមាតុភូមិ DHS នៅ: bit.ly/AAAJ-public-charge ដោយហេតុថា ក្រសួងការពារមាតុភូមិ DHS ភាគច្រើននិងបានឆ្លោយតបពីមតិយោបល់របស់អ្នកបើសិនជាការសរសេររឿងរបស់អ្នកខុសពីគេ សូមលោកអ្នកសរសេរជារឿងរបស់អ្នក និងហេតុផលអ្វីនៃការស្នើសុំផ្លាស់ប្តូរទាំងអស់នេះនិងអាចប៉ះពាល់ទៅលើអ្នក ឬគ្រសាររបស់អ្នក ទៅលើគំរូលិខិតនៅលើគេហទំព័រ(website)នេះ ។
គេហទំព័រ សហាព័ន្ធចុះឈ្មោះ Federal Register website ទទួលយកលិខិតមតិយោបលរបស់អ្នកជាភាសារអង់គ្លេសតែមួយគត់ បើសិនការសរសេរជាភាសារខ្មែរគឺជាការងាយស្រួលសំរាប់អ្នក អ្នកអាចសរសេរលិខិតទាំងអស់នេះជាភាសាររបស់លោកអ្នកដោយមានកាបកស្រាយសិនជាមុនសិននៅពេលដាក់ពាក្រលិ
ខិតនេះចូលទៅ។ អ្នកអាចទាក់ទងតំណាងសមាជ Congressional representative របស់អ្នកនៅលេខទូរស័ព្ទ 202-224-3121 ផងដែល ដើម្បីផ្តល់ដំណឹងថាតើហេតុអ្វីកម្មវីធី សុខភាព ទីលំនៅដ្ឋាន អាហារបំប៉ន យ៉ាងច្រើនទាំងអស់នេះមានសារាក់សំខាន់ទៅលីអ្នក និងក្រុមគ្រសាររបស់អ្នក ហើយសូមប្រាប់ផងដែលថាតើការផ្លាស់ប្តូរទាំងអស់នេះនិងប៉ះពាល់ទៅលើអ្នក បន្ថែមពីលើនេះទៀតសូមអ្នកប្រាប់អំពីសេចក្តីប្រឆាំងរបស់អ្នកនៃការផ្លាស់ប្តូរទាំងអស់នេះផងដែល។ សូមលោកអ្នកជម្រុញនាក់ជិតខាង គ្រសារ និងមិត្តភ័ក្តរបស់អ្នកអោយគាត់ទាំងអស់ផ្តល់មតិយោបល់ ដើម្បីអោយសំលេងរបស់គាត់ទាំងអស់នោះបានឮផងដែល។ យើងនឹងព្យាយាមធ្វើការទាំងអស់គ្នាដើម្បីជាការប្រឆាំងទៅវីញ និងជាការជំទាស់ទៅលើច្បាប់ទាំងអស់នេះដែលអោយទុក្ខទោសមកញាតិសន្តាន និង សហាគមន៍របស់យើងទាំងអស់គ្នា។

## បើសិនជាលោកអ្នកមានការព្រួយបារម្ភ និងមានសំនួរ ឬចង់បានលិខិតគំរូសំរាប់សរសេរសូមទូរសព្ទ័ទៅលេខ:

| ភាសាអង់គ្លេស/ផ្សេងទៀត | ភាសាចិន: | ភាសាហិណ្ឌ: | ភាសាខ្មែរ: |
|---|---|---|---|
| 888.349.9695 | 800.520.2356 | 855.971.2552 | 800.867.3126 |
| **ភាសាកូរ៉េ:** | **ភាសាហ្វីលីពីន:** | **ភាសាថៃ:** | **ភាសាវៀតណាម:** |
| 800.867.3640 | 855.300.2552 | 800.914.9583 | 800.267.7395 |

ASIAN AMERICANS ADVANCING JUSTICE

*This resource was developed by Asian Americans Advancing Justice - Los Angeles, 10/17/18.*